# សេចក្តីថ្លែងការណ៍

## លោកសាស្ត្រាចារ្យ សូយ៉ា ប្រាសាទ ស៊ូប៊ែឌី

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១

ឆ្នាំនេះគឺជាខួបលើកទី២០ នៃការអនុម័តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ ដែលបាននាំមកនូវដំណើរការសន្តិភាពនៅកម្ពុជា។ អាណត្តិរបស់ខ្ញុំក៏បានកើតចេញពីកិច្ចព្រមព្រៀងនេះផងដែរ ។ ចាប់ពីពេលនោះមក កម្ពុជាបានសំរេចសមិទ្ធិផលជាច្រើនគួរឲ្យកត់សំគាល់។ ជម្លោះត្រូវបានដោះស្រាយ សម័យអន្តរកាលត្រូវបានដំណើរការយ៉ាងល្អ ប្រសើរ រដ្ឋធម្មនុញ្ញថ្មីមួយបែបប្រជាធិបតេយ្យត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៣ ហើយការបោះឆ្នោតតាមកាលកំណត់បានប្រព្រឹត្តទៅជាហូរហែរចាប់ពីពេលនោះមក។ វិស័យសេដ្ឋកិច្ច និងនយោបាយមានស្ថិរភាព និង រីកចំរើនជាលំដាប់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលអាចឲ្យប្រជាពលរដ្ឋជាច្រើនចាកផុតពីភាពក្រីក្រ យ៉ាងហោចណាស់ នៅតាមតំបន់ទីប្រជុំនានា ហើយប្រជាពលរដ្ឋមិនត្រឹមតែទទួលបាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផងដែរ ។ និយាយជារួម កម្ពុជាអាចមានមោទនភាពចំពោះសមិទ្ធិផលដែលសំរេចបានទាំងអស់នេះ ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានបង្កើតនីតិរដ្ឋ សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ដែលជាសរសេរទ្រូងដ៏រឹងមាំនៃរចនាសម្ព័ន្ធនយោបាយថ្មីសំរាប់ប្រទេសកម្ពុជា ។ ដូច្នេះ ដំណើរការសន្តិភាព មិនអាចចាត់ទុកថាចប់សព្វគ្រប់បានទេ លុះត្រាតែស្ថាប័នប្រជាធិបតេយ្យទាំងឡាយដែលបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ អាចដំណើរការការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព ។ អាស្រ័យហេតុនេះ សហគមន៍អន្តរជាតិមានតួនាទី និង ទំនួលខុសត្រូវដ៏សំខាន់មួយក្នុងការងារនេះ ។ ក្នុងបរិបទនេះហើយ ទើបបានជាខ្ញុំធ្វើការវាយតំលៃជាប្រព័ន្ធមួយអំពីស្ថាប័នរដ្ឋនានាដើម្បីរកវិធីសាស្ត្រ និង មធ្យោបាយផ្សេងៗក្នុងការជួយពង្រឹងសមត្ថភាព និងឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ ដើម្បីលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ ។ ហេតុដូចនេះហើយ ទើបរបាយការណ៍ចុងក្រោយបំផុត ដែលខ្ញុំនឹងដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ផ្តោតជាសំខាន់លើ

ប្រព័ន្ធតុលាការ ។ ខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាល នឹងពិនិត្យពិចារណាយ៉ាងល្អិតល្អន់លើអនុសាសន៍របស់ខ្ញុំ និងអនុញ្ញាតឲ្យខ្ញុំដឹងអំពីវិធានការនានា ដែលរដ្ឋាភិបាលនឹងចាត់ឡើងក្នុងកិច្ចការនេះ ។

ក្នុងដំណើរបេសសកម្មរបស់ខ្ញុំនាពេលនេះ ខ្ញុំបានផ្តោតជាសំខាន់លើការពិនិត្យលើសមត្ថភាពរបស់សភាក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ និងបទដ្ឋានប្រជាធិបតេយ្យ។ ការទទួលបានសិទ្ធិមនុស្សនៃបុគ្គលគ្រប់រូប គឺអាស្រ័យលើស្ថានភាពប្រជាធិបតេយ្យនៅក្នុងប្រទេស ។ លិទ្ធិប្រជាធិបតេយ្យ គឺមិនមែនត្រឹមតែការរៀបចំឲ្យមានការបោះឆ្នោតតាមកាលកំណត់ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបង្កើតឲ្យមានផងដែរនូវវប្បធម៌ជជែកដេញដោល ពហុបក្ស និងការចូលរួម ។ លិទ្ធិប្រជាធិបតេយ្យមួយ ដែលដំណើរការត្រឹមត្រូវ ទាមទារឲ្យមានមតិប្រឆាំងដ៏មានប្រសិទ្ធភាព។ លិទ្ធិប្រជាធិបតេយ្យមិនសំដៅលើការគ្រប់គ្រងដោយច្បាប់នោះទេ ប៉ុន្តែសំដៅដល់ការអនុវត្តន៍នីតិរដ្ឋ។ ដើម្បីសំរេចបាននូវវិស័យនេះ គេត្រូវបន្តអនុវត្តកិច្ចការជាច្រើន ដូច្នេះហើយបានជាខ្ញុំមកទីនេះ ដើម្បីផ្តល់ការឧបត្ថម្ភគាំទ្រ ។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានវប្បធម៌ចំណាស់ និង មានអារ្យធម៌សម្បូរណ៍រុងរឿងជាងគេនៅក្នុងតំបន់ ប៉ុន្តែបើនិយាយអំពីលិទ្ធិប្រជាធិបតេយ្យ ប្រទេសនេះនៅមានភាពក្មេងខ្ចីនៅឡើយ ហើយអាចទទួលបានអត្ថប្រយោជន៍តាមរយៈការជួយឧបត្ថម្ភគាំទ្រពីមជ្ឈដ្ឋានផ្សេងៗ រាប់ទាំងពីអង្គការសហប្រជាជាតិផងដែរ ។

ក្នុងគោលដៅផ្តល់ជាអនុសាសន៍ក្នុងន័យស្ថាបនាជូនដល់រដ្ឋាភិបាល ខ្ញុំបានតាមឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស ហើយខ្ញុំមានកង្វល់អំពីស្ថានភាពនៃបញ្ហាសិទ្ធិមនុស្សមួយចំនួន ជាពិសេសសេរីភាពក្នុងការសំដែងមតិ និង សិទ្ធិលើដីធ្លី ។ ខ្ញុំយល់ឃើញថា ការសំដែងមតិដោយសន្តិវិធី មិនគួរយកក្រមព្រហ្មទណ្ឌមកធ្វើការដោះស្រាយឡើយ ដែលនៅពេលបច្ចុប្បន្ននេះ មានដូចជា បទបរិហារកេរ្តិ៍ និង បទផ្សាយព័ត៌មានមិនពិត ។ អ្នកដែលកាន់មុខតំណែងសាធារណៈ គួរតែមានឆន្ទៈទទួលយកមតិរិះគន់ ចំពោះការសំរេចចិត្តរបស់ខ្លួន ។ ការរិះគន់មិនមែនជាបទល្មើសនោះទេ ផ្ទុយទៅវិញវាគឺជាការប្រើប្រាស់សេរីភាពខាងសម្បជញ្ញៈ ជាទង្វើមួយនៃការយល់ឃើញ ។ ខ្ញុំជឿថា ការរិះគន់រិតតែមានប្រយោជន៍ថែមទៀត កាលបើការរិះគន់នោះធ្វើឡើងក្នុងន័យស្ថាបនា និង មានការគោរពគ្នា ។ ពាក្យសំដីបង្អាប់បន្តុះ គ្មានប្រយោជន៍សំរាប់កិច្ចសន្ទនានោះទេ ។ ទាំងនេះ គឺជាគោលគំនិតចម្បងៗមួយចំនួន ដែលខ្ញុំបានប្រើជាមូលដ្ឋានគ្រឹះដើម្បីសន្ទនាជាមួយសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតរបស់រដ្ឋាភិបាល ។ ខ្ញុំមានការពេញចិត្តចំពោះការឆ្លើយតបទៅនឹងបញ្ហាមួយចំនួនដែលខ្ញុំបានលើកឡើង។

ខ្ញុំមានកង្វល់អំពីបរិយាកាសដ៏តូចចង្អៀតសំរាប់ប្រជាពលរដ្ឋ ក្នុងការបញ្ចេញមតិរបស់ខ្លួនដោយសន្តិវិធី និងគ្មានការភ័យខ្លាច រាប់ទាំងបុគ្គលទាំងឡាយដែលនៅខាងគណបក្សនយោបាយផ្សេងៗ។ ខ្ញុំមានកង្វល់ជាពិសេស ក្នុងបញ្ហានេះ អំពីការប្រើប្រាស់បទញុះញង់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនានា ។ តាមទស្សនៈរបស់ខ្ញុំ តួអង្គនយោបាយ និងអង្គការសង្គមស៊ីវិល គួរតែ

ធ្វើការឆ្ពោះទៅបង្កើតបរិយាកាសមួយ ដែលផ្តល់ភាពងាយស្រួល ឲ្យបុគ្គលគ្រប់រូបទទួលបានសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់ជាប្រយោជន៍ដល់បុគ្គលគ្រប់រូប ។

រដ្ឋាភិបាលបានសម្រេចនូវសមិទ្ធិផលជាច្រើន ក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស។ កិច្ចខិតខំប្រឹងប្រែងក្នុងការកសាងក្របខណ្ឌគតិយុត្តិ និង ប្រព័ន្ធយុត្តិធម៌ឡើងវិញ (សឹងតែពីបាតដៃទទេ) ចាប់តាំងពីឆ្នាំ១៩៩៣មក គឺជាតួយ៉ាងគួរឲ្យកត់សំគាល់។ ឧទាហរណ៍មួយទៀត គឺការងារដែលអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការបង្កើតក្របខណ្ឌច្បាប់ និង គោលនយោបាយដ៏ទូលំទូលាយមួយ ទាក់ទិននឹងបញ្ហាសិទ្ធិដីធ្លី និងលំនៅដ្ឋាន។ ក្រសួងមហាផ្ទៃ បានធ្វើជាគំរូយ៉ាងល្អមួយ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធកែប្រែ ការបង្កើតឲ្យមានយន្តការបង្ការទារុណកម្ម ព្រមទាំងបង្កើន និងអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ នៅពេលថ្មីៗនេះ ក្រសួងនេះបានចូលរួមក្នុងកិច្ចប្រឹក្សាយោបល់ដ៏មានផ្លែផ្កាមួយ ជាមួយអង្គការសង្គមស៊ីវិល ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និង សមាគម ។ ខ្ញុំសង្ឃឹមថា ក្រសួងមហាផ្ទៃនឹងទទួលយកការប្រឹក្សាយោបល់នេះ ដើម្បីជំរុញឲ្យសេចក្តីព្រាងច្បាប់នេះស្របទៅតាមបទដ្ឋានអន្តរជាតិនានា។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាកំពុងបូកសរុបរបាយការណ៍របស់រដ្ឋាភិបាល ដើម្បីដាក់ជូនអង្គការសហប្រជាជាតិ ទាក់ទិននឹងកាតព្វកិច្ចនានារបស់ខ្លួន ក្រោមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ហើយនិងកំពុងអនុវត្តអនុសាសន៍នានានៃការពិនិត្យរបាយករណ៍ជាសកលតាមកាលកំណត់។

ប្រការមួយទៀតក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ខ្ញុំជាមួយសម្តេចនាយករដ្ឋមន្ត្រី គឺការបង្កើតយន្តការមួយដែលអាចធ្វើទៅបាន សម្រាប់កិច្ចសន្ទនារវាងរដ្ឋាភិបាល និង សង្គមស៊ីវិល ដូចដែលបានស្នើឡើងដោយក្រុមអង្គការមិនមែនរដ្ឋាភិបាលនានា។ សម្តេចនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីសារៈសំខាន់ដែលថាយន្តការបែបនោះ គួរតែបើកទូលាយឲ្យការចូលរួមពីអង្គការសង្គមស៊ីវិលឲ្យបានច្រើនជាងនេះថែមទៀត តាមតែអាចធ្វើទៅបាន។ ខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋាភិបាល និង សង្គមស៊ីវិល បន្តធ្វើការសន្ទនា លើដំណើរការនេះ ឈានទៅបង្កើតយន្តការប្រឹក្សាយោបល់ជាទៀងទាត់មួយ។

សរុបសេចក្តីមក ខ្ញុំទទួលបានកំរិតកិច្ចសហការមួយល្អពីរាជរដ្ឋាភិបាល ។ កិច្ចសន្ទានារបស់ខ្ញុំជាមួយសម្តេចនាយករដ្ឋមន្ត្រី និង ទេសរដ្ឋមន្ត្រីដទៃទៀត គឺដោយចំហរ មិនមានការលាក់លាម និងស្និទ្ធស្នាល ហើយយើងបានឯកភាពគ្នា បន្តកិច្ចសហប្រតិបត្តិការតទៅទៀត។ ក្នុងជំនួបប្រជុំជាច្រើនទៀត ជាមួយសមាជិកសភា និងសមាជិកព្រឹទ្ធសភា តំណាងគណបក្សនយោបាយ និង តំណាងសង្គមស៊ីវិលផ្សេងៗបានទទួលលទ្ធផលជាផ្លែផ្កា ។ ខ្ញុំបានជួបពិភាក្សាដោយផ្ទាល់ជាមួយជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្ស ធ្វើឲ្យខ្ញុំបានយល់អំពីភាពទន់ខ្សោយដែលនៅមាននៅឡើយក្នុងការអនុវត្តន៍ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិនៅក្នុងប្រទេស។

កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស ច្រើនជាងបណ្តារដ្ឋជាច្រើនដទៃផ្សេងទៀត ហើយបានទទួលយកអនុសាសន៍ទាំងអស់ ដែលបានធ្វើឡើងនៅក្នុងដំណើរការត្រួតពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់នៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ កម្ពុជាគឺជាប្រទេសមួយចក្ខុវិស័យឆ្ពោះទៅមុខ ដែលមានរដ្ឋធម្មនុញ្ញមួយបែបប្រជាធិបតេយ្យ ។ ជាក់ស្តែងណាស់ កម្ពុជាមានបញ្ហាប្រឈមផ្សេងៗ ធៀបទៅនឹងរដ្ឋដទៃផ្សេងទៀត ដោយសារ ប្រទេសនេះបានជួបប្រទះនូវភាពរឹករវខ្លះក្នុងប្រវត្តិអតីតកាល ។ កម្ពុជាប្រាថ្នាចង់ក្លាយជាប្រទេសមួយគំរូគេ ក្នុងទិសដៅរស់នៅក្នុងភាពជាឧទាហរណ៍ល្អ ។ វត្តមានរបស់អង្គការសហប្រជាជាតិ និងយន្តការសិទ្ធិមនុស្សនៅកម្ពុជា គឺជាប្រការមួយល្អសំរាប់ប្រទេសកម្ពុជា ។ ដៃគូសន្ទនាជាច្រើន យល់ស្របជាមួយខ្ញុំអំពីបញ្ហានេះ ។ ការគោរពគ្នាទៅវិញទៅមក ហើយជាការពិតណាស់ គោលដៅរិះគន់ក្នុងន័យស្ថាបនាគឺជាមូលដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការ ។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណសម្តេចនាយករដ្ឋមន្ត្រី និង សមាជិកដទៃទៀតនៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា តំណាងសង្គមស៊ីវិល សមាជិកសហគមន៍អ្នកការទូត ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ ក្រុមអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចំពោះកិច្ចសហការ ការទទួលស្វាគមន៍ និងការគាំទ្រដល់រូបខ្ញុំ នៅក្នុងអំឡុងពេលបំពេញបេសកកម្មនៅកម្ពុជា ។

ចប់

លោកសាស្ត្រាចារ្យ **សូយ៉ា ប្រាសាទ ស៊ូប៊ែឌី** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិជ្រើសតាំងជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩ ។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យ ផ្នែកនីតិអន្តរជាតិ នៅសាកលវិទ្យាល័យលីដស៍ នៅចក្រភពអង់គ្លេស ។

រាល់សំណើព័ត៌មានទាំងឡាយទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចផ្ញើមកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ។ សូមមេត្តាទាក់ទងមកកញ្ញា ហ្សីអ៊ី ឡាធំបូ ទូរស័ព្ទលេខ *Tel: +855 012790178 / email: zlatumbo@ohchr.org)* ឬមកលោក ទូច ហួន ទូរស័ព្ទលេខ*Tel: +855 012 476 493 / email: htouch@ohchr.org).*